**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ ៤៨៩៥ អយក.អបក**

ថ្ងៃ ព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩

**ជម្រាបមក**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង**

**កម្មវត្ថុៈ** ការបើកវេទិកាថ្នាក់រៀនស្តីអំពី «សារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» នៅតាមវិទ្យាល័យ ចំនួន១០ ក្នុងខេត្តព្រៃវែង។

**យោង** ៖ -លិខិតស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងវិទ្យាស្ថានស្លឹករឹត ចុះថ្ងៃពុធ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមលោកប្រធានជ្រាបថាៈ មជ្ឈមណ្ឌលឯកសារកម្ពុជា និងវិទ្យាស្ថានស្លឹករឹតនឹងរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «សារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» ជាមួយសិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ នៅតាមវិទ្យាល័យចំនួន១០ ក្នុងខេត្តព្រៃវែង។ កម្មវិធីនេះនឹងចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ខែកក្កដា ឆ្នាំ២០២០(តារាងជូនភ្ជាប់)។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធានសហការចូលរួមជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងវិទ្យាស្ថានស្លឹករឹត ដើម្បីអនុវត្តការងារប្រកបដោយជោគជ័យ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**អនុរដ្ឋលេខាធិការ**

**ឆន់ សារឹម**

ចម្លងជូនៈ
-សាលាខេត្តព្រៃវែង
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានអប់រំ
-អង្គភាពពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-កាលប្បវត្តិ
-ឯកសារ នា.មចទ